ស្ថាដៃសិក្ខាកាម

# តុលាការកំពូលបដិសេធសំណើសុំដោះលែងរបស់សកម្មជនមាតាធម្មជាតិទាំង៥រូប



រថយន្តពន្ធនាគារដឹកសកម្មជនចលនាមាតាធម្មជាតិត្រឡប់ទៅកាន់ពន្ធនាគារវិញ ព្រឹកថ្ងៃទី២ ខែមីនា ឆ្នាំ២០២៦។ (រូបភាព៖ អន ស្រីឡែន)

02 មីនា 2026 4:48 PM ដោយ: អន ស្រីឡែន

នៅព្រឹកថ្ងៃចន្ទនេះ តុលាការកំពូលសម្រេចបដិសេធសំណើរសុំដោះលែងឱ្យមានសេរីភាពរបស់សកម្មជនចលនាមាតាធម្មជាតិទាំ៥រូប ដែលត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារពី៦ ទៅ៨ឆ្នាំ ដោយតម្កល់សេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ទុកជាបានការដដែល។

ចៅក្រមនៃតុលាការកំពូល លោក សាលី ធារ៉ា បានសម្រេចតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការ ដោយបដិសេធមិនដោះលែងសកម្មជនបរិស្ថានទាំង ៥រូប។ កាលពីថ្ងៃទី២៣ ខែកុម្ភៈ តុលាការកំពូលបានបើកសវនាការជំនុំជម្រះលើបណ្តឹងសារទុក្ខរបស់សកម្មជនចលនាមាតាធម្មជាតិទាំង៥រូប។

ក្នុងចំណោមសកម្មជនទាំង៥ លោក **យឹម លាងហ៊ី** និងលោក **ថុន រដ្ឋា** បានបង្ហាញមុខនៅក្នុងសវនាការព្រឹកនេះ ខណៈសកម្មជន ៣រូបទៀត មិនបានបង្ហាញខ្លួននៅតុលាការទេ។

អ្នកនាង ស៊ុន រដ្ឋា ជាសមាជិកម្នាក់ក្នុងចំណោមសមាជិកចលនាមាតាធម្មជាតិ១០ រូប ដែលសាលាដំបូងរាជធានីភ្នំពេញបានផ្តន្ទាទោសកាលពី ០២ ខែកក្កដា ឆ្នាំ២០២៤ និងកំពុងគេចខ្លួនបានប្រាប់ Press start Cambodia ថា ស្ថានភាពនេះ ធ្វើឱ្យប្រជាពលរដ្ឋកម្ពុជាមើលឃើញកាន់តែច្បាស់ និងកាន់តែបាត់បង់ជំនឿលើប្រព័ន្ធតុលាការ។

អ្នកនាងនិយាយថា ៖“***តុលាការកាន់តែបង្ហាញឱ្យប្រជាពលរដ្ឋកម្ពុជាមើលឃើញកាន់តែច្បាស់និងអស់ជំនឿចិត្តកាន់តែខ្លាំងឡើងពីប្រព័ន្ធតុលាការ ហើយជាពិសេសឱ្យមើលឃើញកាន់តែច្បាស់ពីប្រព័ន្ធដឹកនាំរបស់កម្ពុជាថា តើប្រព័ន្ធតុលាការនៅកម្ពុជាមានទំនោរទៅខាងណា*** ”។

លោក ឡូយ យឹម វ័យ ៦៩ឆ្នាំ ជាឪពុកលោក យឹម លាងហ៊ី ដែលបានចូលស្តាប់ការប្រកាសសាលដីកាយល់ថា ការចោទប្រកាន់នេះ គឺជាការបំបិទសំឡេង ជំនួសឱ្យការលើកទឹកចិត្តនិងគាំទ្រពួកគេ។

លោកនិយាយថា ៖“***ពេលដែលចោទនេះ គឺដូចជា គឺចាដូចមិនមានភស្តុតាង ច្បាស់លាស់ទេ ។ ចោទហ្នឹងដូចថា មានកំហឹងឈឺចាប់ តូចចិត្តនឹងយុវជនដែលគ្នាបានខំធ្វើការហើយមានទាំងពានរង្វាន់ពិភពលោកគេឱ្យ ហើយដូចថា មិនលើកទឹកចិត្តគ្នាបែរទៅចាប់កំហុសគ្នា ។ ចឹងបានន័យថា ធ្វើបំបាក់ទឹកចិត្តយុវជន បំបិតមាត់យុវជន ចឹងមិនល្អទេ***”។

លោកបន្តថា លោកនឹងនៅតែគាំទ្រកូនប្រុសរបស់លោកជានិច្ចមិនហាមឃាត់ទេ ឱ្យតែកូនមានឧត្តមគតិស្នេហាជាតិមាតុភូមិច្បាស់។

អ្នកស្រី ប៉ាត រស្មី ជាភរិយារបស់លោក ថុន រដ្ឋា បានបង្ហាញអារម្មណ៍សោកស្តាយ និងខកចិត្តចំពោះសេចក្តីសម្រេចរបស់តុលាការកំពូលនៅព្រឹកនេះ។

អ្នកស្រីនិយាយថា ៖“***ពិតជាមានអារម្មណ៍សោកស្តាយនិងឈឺចាប់ ឈឺចាប់ខ្លាំងមែនទែន ព្រោះយើងដឹងហើយថា កន្លងមកគាត់ធ្វើការងារ ដើម្បីតែបរិស្ថានសង្គមជាតិ ដើម្បីតែប្រទេសជាតិរបស់យើង ហេតុអីក៏ត្រូវនៅបន្តដាក់គាត់នៅពន្ធនាគារទៀត។ វាជារឿងអយុត្តិធម៌មែនទែន***” ។

កាលពីដើមខែកក្កដា ឆ្នាំ២០២៤ សកម្មជនចលនាមាតាធម្មជាតិទាំង៥រូប មានកញ្ញា ឡុង គន្ធា លោក ថុន រដ្ឋា កញ្ញា ភួន កែវរស្មី លោក លី ចាន់ដារ៉ាវុទ្ធ និងលោក យឹម លាងហ៊ី ត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារពី៦ ទៅ៨ឆ្នាំ ពីបទ “រួមគំនិតក្បត់” និងបទ “ព្រះមាថចំពោះអង្គព្រះមហាក្សត្រ”។

កញ្ញា ហេង គឹមសួ មន្ត្រីគោលនយោបាយនិងតស៊ូមតិ នៃអង្គការភាពជាដៃគូរ ដើម្បីបរិស្ថាននិងការអភិវឌ្ឍ យល់ថា មិនមែនជារឿងថ្មីទេ ដែលតុលាការបដិសេធការស្នើសុំរបស់សកម្មជន ហើយថា ការបន្តចាប់អ្នកការពារបរិស្ថាននិងអ្នកការពារសិទ្ធិមនុស្ស ជះឥទ្ធិពលអាក្រក់ដល់សង្គមកម្ពុជាទៅវិញទេ។

កញ្ញានិយាយថា ៖“***ចំពោះខ្ញុំមិនប្លែកអារម្មណ៍អីទេ ពីព្រោះកន្លងមក គឺយើងឃើញថា ការដែលស្នើសុំនៅក្រៅឃុំតែងតែទទួលបានការបដិសេធ ពីប្រព័ន្ធតុលាការកម្ពុជា***”។

លោក រស់ សារ៉ាត់ អ្នកសម្របសម្រួលគម្រោង នៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) ដែលបានចូលរួមស្តាប់ប្រកាសសាលដីកានេះ ក៏បានសម្តែងការសោកស្តាយផងដែរចំពោះសេចក្តីសម្រេចនេះ ព្រោះសកម្មភាពរបស់សកម្មជនបរិស្ថាន គឺធ្វើដើម្បីប្រយោជន៍ពលរដ្ឋទូទៅ។



Post Views: 23

## អត្ថបទគួរឱ្យចាប់អារម្មណ៍

តុលាការកំពូលច្រានចោលសំណើរសុំនៅក្រៅឃុំរបស់សមាជិកសមាគមសម្ព័ន្ធនិស្សិតបញ្ញវន្តខ្មែរ
27 ឧសភា 2025 12:00 AM

តុលាការកំពូលបដិសេធសំណើសុំដោះលែងរបស់សកម្មជនមាតាធម្មជាតិទាំង៥រូប
02 មីនា 2026 12:00 AM

អង្គការ CIVICUS អំពាវនាវឱ្យដោះលែងសកម្មជនចលនាមាតាធម្មជាតិទាំង៥រូប
28 កុម្ភៈ 2026 12:00 AM

ក្រសួងវប្បធម៌ច្រានចោលការចោទប្រកាន់ថា កម្ពុជាប្រើប្រាស់ប្រាសាទព្រះវិហារជាមូលដ្ឋានយោធា
28 កុម្ភៈ 2026 12:00 AM

តំណាងអាយធាកម្ពុជាលើកឡើងពីផលប៉ះពាល់ដោយសារការវាយប្រហាររបស់កងទ័ពថៃ
28 កុម្ភៈ 2026 12:00 AM

**Press Start Cambodia**

Press Start Cambodia គឺជាគម្រោងដែលអនុវត្តដោយមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) ក្នុងគោលបំណងបណ្តុះបណ្តាលអ្នកសារព័ត៌មានជំនាន់ក្រោយនៅកម្ពុជា។ គម្រោងនេះ ផ្តល់វគ្គបណ្តុះបណ្តាលផ្នែកសារព័ត៌មានក្រៅម៉ោងរយៈពេល 4 ខែ ដែលរួមបញ្ចូលគ្នានូវការសិក្សាក្នុងថ្នាក់រៀន ការអនុវត្តផ្ទាល់ ការចុះកម្មសិក្សា និងឱកាសហាត់ការ ដើម្បីជំរុញឲ្យសិក្ខាកាមអភិវឌ្ឍជំនាញមូលដ្ឋាននៃសារព័ត៌មាន និងទទួលបានបទពិសោធន៍ជាក់ស្តែងក្នុងវិស័យសារព័ត៌មាន។ គេហទំព័រនេះគឺសម្រាប់ផ្សព្វផ្សាយស្នាដៃរបស់សិក្ខាកាម Press Start Cambodia ក្នុងអំឡុងពេលបណ្តុះបណ្តាល រួមទាំងអត្ថបទដែលផលិតដោយអតីតសិក្ខាកាមបណ្តុះបណ្តាលផ្នែកសារព័ត៌មាន ដែលគាំទ្រដោយជំនួយអត្ថបទពីCCIM។

**ទំនាក់ទំនង**

ផ្ទះលេខ 14A ផ្លូវ 392 បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
អ៊ីមែល៖ pressstartcambodia@ccimcambodia.org

**បណ្តាញសង្គម**

© ២០២៥ រក្សាសិទ្ធិគ្រប់យ៉ាងដោយ Press Start Cambodia